# សិក្ខាសាលាបើកដំណើរការគម្រោង
# “ថ្នាលឧត្តមចំណេះ៖ ការប្រមើលមើលឡើងវិញអំពីការអប់រំនាពេលអនាគតរបស់កម្ពុជា”
# និង
# សិក្ខាសាលាស្តីពីការធ្វើសុពលភាពការស្រាវជ្រាវ

ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០២១

តាមប្រព័ន្ធអនឡាញ Zoom

**ឯកសារទេស្សនៈទាន**

## សេចក្តីផ្តើម

ជំងឺរាតត្បាតកូវីដ ១៩ បាននាំមកនូវការរអាក់រអួលផ្នែកអប់រំពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា និងនៅជុំវិញពិភពលោក។ ផលប៉ះពាល់នៃជំងឺរាតត្បាតនៅកម្ពុជាមានកម្រិតទាប បើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតក្នុងឆ្នាំ២០២០។ ដោយហេតុនេះ ទើបសាលារៀនអាចបើកទ្វារឡើងវិញនៅដើមឆ្នាំ២០២១។ ជាអកុសល ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈបានធ្វើឱ្យចំនួនករណីកូវីដ ១៩កើនឡើងជាលំដាប់ ហើយស្ថាប័នអប់រំត្រូវបានបង្ខំឱ្យបិទទាំងស្រុង។ ដោយសារកិច្ចខិតខំប្រឹងប្រែងដ៏ធំធេងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា និងដោយមានការគាំទ្រយ៉ាងខ្លាំងពីដៃគូអភិវឌ្ឍន៍ សិស្សនិស្សិតអាចបន្តការសិក្សាពីចម្ងាយតាមរយៈមធ្យោបាយផ្សេងៗដូចជា ការសិក្សាតាមអ៊ីនធឺណិត ទូរទស្សន៍ជាតិ និងការផ្សាយតាមវិទ្យុ។ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI)បានចាប់ផ្តើមអនុវត្តន៍កម្មវិធីថ្មីដែលមានរយៈពេលពីរឆ្នាំមានឈ្មោះថា **“ថ្នាលឧត្តមចំណេះ៖ ការប្រមើលមើលឡើងវិញអំពីការអប់រំនៅកម្ពុជានាពេលអនាគត”** សម្រាប់ឆ្នាំ ២០២១ ដល់ ២០២៣។ គម្រោងស្រាវជ្រាវនេះត្រូវបានឧបត្ថម្ភថវិកាដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) នៃប្រទេសអូស្ត្រាលី និងតាមរយៈមូលនិធិអាស៊ីក្នុងដំណាក់កាលទី២។ នេះគឺអនុលោមតាមអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការកសាងប្រព័ន្ធអប់រំឱ្យមានភាពធន់បន្ទាប់ពីកូវីដ ១៩ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលអូស្ត្រាលីក្នុងការបង្កើតចំណេះដឹង និងគំនិតថ្មីៗសម្រាប់ការពិភាក្សាអំពីគោលនយោបាយសាធារណៈ។ កម្មវិធីថ្មីនេះមានគោលបំណង៖ (១) ផលិតឯកសារស្រាវជ្រាវដែលមានគុណភាពខ្ពស់ ឯករាជ្យ និងពាក់ព័ន្ធនឹងគោលនយោបាយដើម្បីជះឥទ្ធិពលដល់កំណែទម្រង់វិស័យអប់រំនៅប្រទេសកម្ពុជា; (២) លើកកម្ពស់វប្បធម៌ស្រាវជ្រាវនៅកម្ពុជា និងលើសពីនេះតាមរយៈការកសាងសមត្ថភាព និងសកម្មភាពផ្លាស់ប្តូរការស្រាវជ្រាវ; (៣) បង្កើតចំណេះដឹងជំនាញនិងសមត្ថភាពរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បី

អភិវឌ្ឍន៍កម្ពុជា (CDRI) និងដៃគូរបស់ខ្លួន; និង(៤) បង្កើតភាពជាដៃគូសហការ និងបណ្តាញសម្រាប់គោលនយោបាយ និងការពិភាក្សាអាហារូបករណ៍ និងការស្រាវជ្រាវរវាងវិទ្យាស្ថាន CDRI និងភាគីពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេសកម្ពុជា។

ជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវរយៈពេល ២.៥ ឆ្នាំ (២០១៩-២០២២) ក្នុងដំណាក់កាលដំបូងដែលទទួលបានការគាំទ្រដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) តាមរយៈមូលនិធិអាស៊ី។ វិទ្យាស្ថាន CDRI បានធ្វើការសិក្សាស្រាវជ្រាវមួយ ដើម្បីវាយតម្លៃពីការត្រៀមខ្លួន កត្តាកំណត់ និងចន្លោះប្រហោងក្នុងការទទួលយកបច្ចេកវិទ្យាថ្មីនៅគ្រឹះស្ថានឧត្តមសិក្សា និងបណ្តុះបណ្តាលនៅកម្ពុជា។ ការស្ទង់មតិឯករាជ្យពីរត្រូវបានធ្វើឡើងក្នុងចំណោមគ្រូចំនួន ៣៧០ នាក់មកពីគ្រឹះស្ថានឧត្តមសិក្សាចំនួន ១៨ និងនិស្សិតចំនួន ១ ៣៣៨ នាក់មកពីគ្រឹះស្ថានឧត្តមសិក្សាចំនួន ២២ នៅចន្លោះខែមិថុនា និងកក្កដា ២០២០។ លទ្ធផលវិភាគជាបឋមនៃការសិក្សានោះ នឹងត្រូវបង្ហាញ និងពិភាក្សានៅក្នុងសិក្ខាសាលានេះ។

## គោលបំណង

គោលបំណងចម្បងនៃសិក្ខាសាលាថ្នាក់ជាតិនេះមានពីរគឺ៖

- ដើម្បីបើកដំណើរការគម្រោងស្រាវជ្រាវដែលគាំទ្រដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) តាមរយៈគម្រោង ពន្លកចំណេះដំណាក់កាលទី២ របស់មូលនិធិអាស៊ី និងជូនដំណឹងដល់ដៃគូ ក៏ដូចជាភាគីពាក់ព័ន្ធរបស់ វិទ្យាស្ថាន CDRI អំពីប្រធានបទស្រាវជ្រាវ និងសកម្មភាពនៃគម្រោងថ្មី
- ដើម្បីចែករំលែកការរកឃើញបឋមពីការសិក្សាលើ "ការប្រើប្រាស់ដោយបង្ខំនូវបច្ចេកវិទ្យាអប់រំ (EdTech) នៅតាមគ្រឹះស្ថានឧត្តមសិក្សាក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ១៩" និងដើម្បីទទួលបានមតិពីអ្នកពាក់ព័ន្ធសំខាន់ៗ (ជាពិសេសស្ថាប័នឧត្តមសិក្សាដែលបានចូលរួមក្នុងការសិក្សា និងនាយកដ្ឋានឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា)

## អ្នកចូលរួម

អ្នកចូលរួមប្រមាណ ៣០ នាក់មកពីមូលនិធិអាស៊ី ក្រសួងអប់រំយុវជននិងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សានិងTVET អ្នកស្រាវជ្រាវ និងអ្នកអនុវត្តគោលនយោបាយពីដៃគូស្នូលរបស់ពន្លកចំណេះ ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិលដទៃទៀត ត្រូវបានរំពឹងថា នឹងចូលរួមក្នុងសិក្ខាសាលានេះ។

**កម្មវិធី**

| | |
|---|---|
| 7:45 – 8:00 | *ចុះឈ្មោះសិក្ខាកាម* |
| 8:00 – 8:30 | **មតិស្វាគមន៍ និងបើកកម្មវិធី**<br>- **មតិស្វាគមន៍**<br>**អ្នកស្រីបណ្ឌិត អេង នេត្រា** នាយកប្រតិបត្តិ នៃវិទ្យាស្ថាន CDRI<br>- **សុន្ទរកថាបើក**<br>**លោក** Andreas Zurbrugg ឯកអគ្គរដ្ឋទូតរង និង ប្រធានផ្នែកជំនួយអភិវឌ្ឍន៍ប្រចាំស្ថានទូតអូស្ត្រាលី<br>**លោកស្រី** Meloney Lindberg តំណាងប្រចាំប្រទេសនៃអង្គការមូលនិធិអាស៊ី |
| 8:30 – 8:35 | **ថតរូបជាក្រុម** |
| 8:35 – 9:35 | **ការចាប់ផ្ដើមគម្រោង "ថ្នាលឧត្តមចំណេះ៖ ការប្រមើលមើលឡើងវិញ អំពីការអប់រំនៅកម្ពុជានាពេលអនាគត"**<br>- ការធ្វើបទបង្ហាញពីគម្រោងថ្មីដោយ**បណ្ឌិត ជា ផល** អ្នកស្រាវជ្រាវមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ នៃវិទ្យាស្ថានCDRI<br>- សំណួរ និងចម្លើយ |
| 9:35 – 9:45 | **សម្រាក** |
| 9: 45 – 10:45 | **ការធ្វើសុពលភាពនៃការស្រាវជ្រាវ៖ "ការប្រើប្រាស់ដោយបង្ខំនូវបច្ចេកវិទ្យាអប់រំ (EdTech) នៅតាមគ្រឹះស្ថានឧត្តមសិក្សាក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ១៩"**<br>- បទបង្ហាញពីលទ្ធផលបឋមពីការសិក្សាស្រាវជ្រាវ ដោយ**បណ្ឌិត សាំង ច័ន្ទហង្ស** អ្នកប្រឹក្សាស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI<br>- សំណួរ និងចម្លើយ |
| 10:45-11:00 | សុន្ទរកថាបិទដោយ **ឯកឧត្តម ម៉ក់ ងយ** អគ្គនាយកនៃនាយកដ្ឋានឧត្តមសិក្សា |

**បញ្ជាក់៖ កម្មវិធីនេះអាចមានការផ្លាស់ប្ដូរតាមការចាំបាច់**